**Tenancy Services**

# តើអ្នករស់នៅផ្ទះជួលដែល មានផ្តល់សេវាបន្ថែមមែនទេ? យល់ដឹងពីសិទ្ធិរបស់អ្នក

សូមចូលមើលវ៉ិបសាយថ៍របស់យើងតាមអាសយដ្ឋានៈ
www.tenancy.govt.nz/tenants-boarding-houses

ឬហៅទូរស័ព្ទទៅលេខ
0800 TENANCY (0800 836 262)

MINISTRY OF BUSINESS,
INNOVATION & EMPLOYMENT
HĪKINA WHAKATUTUKI

# អ្វីទៅជាផ្ទះជួលដែលមានផ្តល់សេវាបន្ថែម?

- គឺជាលំនៅដ្ឋានដោយមានបន្ទប់ជួលមួយ ឬច្រើន ដែលមានផ្តល់សេវាបន្ថែម និង
- មានសម្ភារៈសម្រាប់អ្នកជួលប្រើប្រាស់រួមគ្នា និង
- មានអ្នកជួលនៅ ឬនឹងមានអ្នកជួលនៅយ៉ាងហោចណាស់ ចំនួន 6នាក់ នៅក្នុងពេលណាមួយ។



## តើអ្វីទៅជាការជួលផ្ទះដែលមានផ្តល់សេវាបន្ថែម?

ការជួលផ្ទះនៅដែលមានផ្តល់សេវាបន្ថែមមានរយៈពេល ឬការមានបំណងជួលផ្ទះដែលមានផ្តល់សេវាបន្ថែមដើម្បីរស់នៅយ៉ាងហោចណាស់ចំនួន 28ថ្ងៃ ហើយអ្នកជួលមាន៖

- សិទ្ធិទាំងស្រុងដើម្បីកាន់កាប់បន្ទប់គេងរបស់ពួកគេ
- ប្រើប្រាស់សម្ភារៈរួមគ្នា ។

## ម្ចាស់ផ្ទះជួលដែលមានផ្តល់សេវាបន្ថែមត្រូវតែ ៖

- ធានាថាបន្ទប់សម្រាប់ជួលមានភាពស្អាតសមរម្យនៅមុនពេលអ្នកចាប់ផ្តើមជួល។
- ធានាថាសម្ភារៈសម្រាប់ប្រើប្រាស់រួមគ្នាត្រូវមានសភាពស្អាតសមរម្យ ។
- ថែទាំផ្ទះ និងជួសជុលតាមភាពចាំបាច់ ។
- សរសេរ និងប្រាប់អ្នកឲ្យបានដឹងមុន យ៉ាងហោចណាស់ចំនួន 28ថ្ងៃ នៅមុនពេលពួកគេដាក់ផ្ទះជួល។
- ប្រាប់ដំណឹងតាមច្បាប់ដល់អ្នកជួលឲ្យបានដឹងជាមុនដើម្បីចូលក្នុងបន្ទប់ជួល ។
- អនុវត្តតាមតម្រូវការឲ្យដាក់សៀវភៅរែនរោទ៍នៅពេលមានផ្សែងទាំងអស់។
- អនុវត្តតាមតម្រូវការរបស់អាគារ សុខភាព និងសុវត្ថិភាពទាំងអស់។

កំណត់ចំណាំ៖ ច្បាប់ស្តីពីការជួលលំនៅដ្ឋានឆ្នាំ1986មិនអាចអនុវត្តបាន ចំពោះអ្នកដែលគ្រោងស្នាក់នៅតិចជាង 28ថ្ងៃឡើយ ។ ក៏ប៉ុន្តែ មជ្ឈមណ្ឌលច្បាប់សហគមន៍ និងការិយាល័យផ្តល់ឱវាទដល់ពលរដ្ឋអាចផ្តល់ឱវាទទាក់ទងនឹងស្ថានភាពទាំងនេះដល់អ្នកបាន។

# មានចំណុចគន្លឹះចំនួន 11 សម្រាប់អ្នកជួលផ្ទះដែលមានសេវាបន្ថែម

1. យល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក និងរបៀបទាក់ទងជាមួយយើងខ្ញុំ (សូមអាននៅទំព័រម្ខាងទៀត)។
2. មានកិច្ចព្រមព្រៀងជួលផ្ទះជាលាយលក្ខណ៍អក្សរ។
3. អនុវត្តតាមវិន័យក្នុងផ្ទះ។
4. យកបង្កាន់ដៃនៅពេលណាដែលអ្នកបង់ថ្លៃឈ្នួលផ្ទះ ឬប្រាក់បង់ធានា។
5. បង់ថ្លៃឈ្នួលផ្ទះឲ្យបានទៀងទាត់។
6. ប្រាប់ម្ចាស់ផ្ទះប្រសិនបើមានអ្វីត្រូវជួសជុល។
7. ម្ចាស់ផ្ទះអាចចូលបន្ទប់របស់អ្នកបានតែនៅក្នុងកាលៈទេសៈជាក់លាក់ប៉ុណ្ណោះ។
8. ប្រាប់ម្ចាស់ផ្ទះឲ្យបានដឹងចំនួន 48 ម៉ោងមុនពេលអ្នកចង់រើចេញពីផ្ទះ។
9. ធ្វើឲ្យប្រាកដថាម្ចាស់ផ្ទះប្រាប់អ្នកជាមុនក្នុងរយៈពេលត្រឹមត្រូវនៅពេលគេប្រាប់ឲ្យអ្នករើចេញពីផ្ទះ។
10. ក្នុងករណីភាគច្រើន ម្ចាស់ផ្ទះអាចបញ្ឈប់ការជួលផ្ទះបានដោយប្រាប់អ្នកឲ្យដឹងមុនចំនួន 28ថ្ងៃ ។
11. សូមកុំរំខានដល់សេចក្តីសុខ ផាសុកភាព ឬសិទ្ធិឯកជនសមស្របរបស់អ្នកជួលផ្ទះផ្សេងទៀត។

---

New Zealand Government